**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរ៉ែ និង ថាមពល**
**អគ្គនាយកដ្ឋានធនធានរ៉ែ**
**នាយកដ្ឋានគ្រប់គ្រងការស្វែងរុករករ៉ែ**

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១៦

# ស្ថានភាពនៃការសិក្សាស្រាវជ្រាវរ៉ែមាសនៅកម្ពុជា

## ១. លក្ខណៈទូទៅនៃស្ថានភាពរ៉ែនៅកម្ពុជាមុនឆ្នាំ១៩៧៩ តើមានសណ្ឋាន និងសភាពបែបណាខ្លះ ?

តាមលទ្ធផលនៃការសិក្សាស្រាវជ្រាវរ៉ែ និងភូគព្ភសាស្ត្រ ដែលបានធ្វើឡើងដោយវិស្វករភូគព្ភសាស្ត្របារាំង និងចិន នៅពាក់កណ្តាលទសវត្សទី ១៩ បានបង្ហាញឲ្យឃើញថា នៅកម្ពុជាអាចនឹងមានសក្តានុពលរ៉ែជាច្រើន (វិស្វករទាំងនោះបានរកឃើញរ៉ែ និងសន្ទស្សន៍ (ចំណុច) រ៉ែ (Index) ជាច្រើនកន្លែងនៅកម្ពុជា ដូចជា ដែក មាស ត្បូង បុកស៊ីត ម៉ង់កាណែស ធ្យូងថ្ម ខ្សាច់ស ថ្មកំបោរ ថ្មហ្វូស្វាត និងថ្មសម្រាប់បំរើឲ្យការសាសង់ (ក្រួស ខ្សាច់សំណង់ ក្រានីត រីយ៉ូលី) ។ល។ ប៉ុន្តែនៅពេលនោះ រ៉ែ និងសន្ទស្សន៍ (ចំណុច) រ៉ែ ដែលអ្នកវិស្វករទាំងនោះបានរកឃើញនៅតាមទីតាំងនីមួយៗ ពុំទាន់ត្រូវបានសិក្សាលំអិត និងវាយតម្លៃថា តើវាមានបរិមាណរ៉ែប៉ុន្មាន? តើអាចមានលក្ខណៈសេដ្ឋកិច្ច (ចំណេញ) ដែលអាចធ្វើអាជីវកម្មបានដែរឬទេ?

តាមសៀវភៅរៀនអាន ឬសៀវភៅភូមិសាស្ត្រ ដែលត្រូវបានយកមកបង្រៀនដល់សិស្សនៅថ្នាក់បឋមសិក្សា និងវិទ្យាល័យ ដែលបានបោះពុម្ពផ្សព្វផ្សាយដោយគ្រឹះស្ថានអប់រំជាតិ បានបង្ហាញឲ្យដឹង (ទាំងគេ ទាំងខ្ញុំកាលនៅវ័យកុមារនៅពេលនោះបានដឹងថា) ប្រទេសកម្ពុជា ជាប្រទេសដែលសម្បូទៅដោយធនធានរ៉ែ មានដូចជា ត្បូងថ្ម នៅប៉ៃលិន មាសនៅខេត្តកំពង់ធំ ដែកនៅខេត្តព្រះវិហារ ថ្មកំបោរ (សម្រាប់ផលិតស៊ីម៉ងត៍) នៅខេត្តកំពត ថ្មហ្វូសស្វាត (សម្រាប់ផលិតជីហ្វូសស្វាត) នៅខេត្តកំពត ។ល។ ប៉ុន្តែមិនបានបញ្ជាក់ថា សក្តានុពលរ៉ែនីមួយៗ ទាំងនោះមានបរិមាណប៉ុន្មាន? ហើយអាចមានលក្ខខណៈសេដ្ឋកិច្ចដែលអាចធ្វើអាជីវកម្មបានដែរឬទេ?

## ២. តើកម្ពុជាមានរ៉ែ និងសន្ទស្សន៍រ៉ែមាសនៅទីកន្លែងណាខ្លះ?

1.- រ៉ែលោហៈ

- រ៉ែ និងសន្ទស្សន៍រ៉ែមាស (Au) - នៅខេត្តបាត់ដំបង កំពង់ចាម កំពង់ធំ កំពត មណ្ឌលគីរី ព្រះវិហារ រតនគីរី សៀមរាប និងស្ទឹងត្រែង

## ៣. ស្ថានភាពនៃការវិនិយោគនៅក្នុងការសិក្សាស្រាវជ្រាវរ៉ែ ចាប់ពីឆ្នាំ ១៩៩៤ រហូតមកដល់ពេលបច្ចុប្បន្ន

ចាប់ពីឆ្នាំ ១៩៩៤ ដល់ឆ្នាំ ២០១៤ អតីតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បានចាប់ផ្តើមធ្វើការទាក់ទាញវិនិយោគិនក្នុង និងក្រៅប្រទេសបានមួយចំនួន ដើម្បីស្វែងរុករករ៉ែមាស នៅខេត្តព្រះវិហារ

មណ្ឌលគីរី និងរតនគីរី ។ តាមពិតពួកគេពុំមែនជាក្រុមហ៊ុនរ៉ែដែលមានអាជីពខាងឧស្សាហកម្មរ៉ែទេ ប៉ុន្តែគេមានដៃគូមកសហការ ។ ក្នុងគោលបំណងជម្រុញ និងអភិវឌ្ឍន៍វិស័យឧស្សាហកម្មរ៉ែនៅកម្ពុជា ដើម្បីរួមចំណែកនៅក្នុងអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិនោះ នៅពេលនោះទោះបីស្ថានភាពនៅតាមតំបន់ទាំងនោះពុំទាន់មានសន្តិសុខ ១០០% នៅឡើយក្តី ក៏មានក្រុមហ៊ុនរ៉ែមួយចំនួនបានចុះកិច្ចព្រមព្រៀងជាមួយក្រសួងដើម្បីស្វែងរុករករ៉ែនៅតាមតំបន់ដែលក្រសួងសម្បទានឲ្យ ។

ប៉ុន្តែលទ្ធផលនៃការស្វែងរុករករ៉ែពុំអាចធ្វើទៅបានតាមផែនការដែលបានគ្រោងទុក និងទទួលបានជោគជ័យឡើយ ដោយសារបញ្ហាអសន្តិសុខនៅតាមតំបន់ព្រៃភ្នំ និងដាច់ស្រយាល ដែលជាតំបន់ត្រូវធ្វើការសិក្សាស្រាវជ្រាវរ៉ែ ហើយក្រុមហ៊ុនខ្លះក៏សុំបញ្ចប់កិច្ចព្រមព្រៀងជាមួយក្រសួង ហើយក្រុមហ៊ុនខ្លះទៀតក៏ត្រូវក្រសួងបញ្ចប់កិច្ចព្រមព្រៀងនោះវិញដែរ ។ ការបញ្ចប់កិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនទាំងនោះបានពាំនាំទៅជាមួយនូវបំណុលជំពាក់រដ្ឋយ៉ាងច្រើន ដែលក្រុមហ៊ុនទាំងនោះពុំមានលទ្ធភាពសងរដ្ឋទេ ហើយបានកត់ត្រាទុកជាបំណុលរបស់រដ្ឋ រហូតមកសព្វថ្ងៃនេះ ។

បន្ទាប់ពីកម្ពុជាបានទទួលសុខសន្តិភាពពេញលេញនៅឆ្នាំ ១៩៩៩ ចាប់ពីឆ្នាំ ២០០០ មកក៏មិនទាន់មានក្រុមហ៊ុនក្នុង និងក្រៅប្រទេសមកចាប់អារម្មណ៍ទៅនឹងការវិនិយោគស្វែងរុករករ៉ែនៅកម្ពុជាទេ ពីព្រោះយើងក៏ពុំមានទិន្នន័យភូគព្ភសាស្ត្ររ៉ែ និងរបាយការណ៍សិក្សាស្រាវជ្រាវរ៉ែជាក់លាក់ណាមួយសម្រាប់ធ្វើការផ្សព្វផ្សាយទេនៅក្នុងរយៈពេលនោះ ។ ដូច្នេះ ដោយផ្អែកតាមសៀវភៅ Atlas Volume 10 ជាភាសាអង់គ្លេស ដែលបានបោះពុម្ពផ្សាយ ដោយអង្គការ ESCAP ប្រចាំនៅទីក្រុងបាងកក នាឆ្នាំ ១៩៩៥ យើងក៏បានធ្វើការប្រែសម្រួលជាភាសាខ្មែរដើម្បីផ្សព្វផ្សាយនៅក្នុងប្រទេស និង ដើម្បីសិក្សាស្រាវជ្រាវបន្ថែមទៀតនៅថ្ងៃអនាគត ។

## ៤. អាជ្ញាបណ្ណស្វែងរុករករ៉ែមាស និងអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មរ៉ែមាស ដោយគតត្រឹមខែ មេសា ឆ្នាំ ២០១៦

(ក) អាជ្ញាបណ្ណស្វែងរុករករ៉ែមាស - ខ្ញុំបានផ្ញើជូនរួចកាលពីថ្ងៃទី ៣០ មេសា ២០១៦ តាមរយៈអ៊ីម៉ែល។

(ខ) អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មរ៉ែមាស មានក្នុងឧបសម្ព័ន្ធ ជូនភ្ជាប់មកជាមួយនេះ ។

**នាយកដ្ឋានគ្រប់គ្រងការស្វែងរុករករ៉ែ**